01329147

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 21 / 09 / 2016
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

E396/4

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

សាធារណៈ / Public

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១៦

**ជូនចំពោះ៖** ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី៖** ចៅក្រម យ៉ា សុខន ជ.ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ៖** សេចក្ដីសម្រេចលើសំណើរបស់ នួន ជា អនុលោមតាមវិធាន ៨៧(៤) សុំឲ្យទទួលយកជាភស្តុតាងនូវសម្ភារៈពាក់ព័ន្ធនឹងសម្ដេចព្រះបរមរតនកោដ្ឋ ព្រះវររាជបិតា នរោត្ដម សីហនុ

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើមួយ អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ដែលបានដាក់នៅថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៦ (ឯកសារ E396) ("សំណើ") ដោយមេធាវីការពារក្ដី នួន ជា សុំឱ្យទទួលយកជាភស្តុតាងនូវចុតហ្មាយចំនួនបីច្បាប់ សរសេរដោយសម្ដេចព្រះបរមរតនកោដ្ឋ នរោត្ដម សីហនុ ("សម្ដេចព្រះបរមរតនកោដ្ឋ") ព្រមទាំងខ្សែវីដេអូមួយ និង ខ្សែអាត់សំឡេងមួយទៀតទាក់ទិននឹងសុន្ទរកថារបស់ព្រះអង្គ (រួមគ្នាហៅថា "សម្ភារៈ")។ នៅថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១៦ មេធាវីការពារក្ដី ខៀវ សំផន បានដាក់ការគាំទ្រចំពោះសំណើសុំនេះ (ឯកសារ E396/1)។ នៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៦ សហ-ព្រះរាជអាជ្ញាបានដាក់ចម្លើយតបទៅនឹងសំណើសុំ និង ការគាំទ្ររបស់មេធាវីការពារក្ដី ខៀវ

សំផន (ឯកសារ E396/2) ("ចម្លើយតប")។ មេធាវីការពារក្តី នួន ជា បានដាក់សារណាតប នៅថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១៦ (ឯកសារ E396/3) ("សារណាតប")។

២. មេធាវីការពារក្តី នួន ជា បានលើកឡើងថា សម្ភារៈទាំងនេះ ធ្វើឡើងនៅក្រោយរបបកម្ពុជាប្រជាធិបតេយ្យ តែវាបានបង្ហាញពីទស្សនៈរបស់សម្តេចព្រះបរមរតនកោដ្ឋ ស្តីពីជនជាតិវៀតណាម និង ការឈ្លានពានរបស់វៀតណាមលើប្រទេសកម្ពុជា។ មេធាវីការពារក្តីលើកឡើងផងដែរថា សម្ភារៈទាំងនេះគឺជាប់ពាក់ព័ន្ធទៅនឹងភាពអាចជឿជាក់បានរបស់អ្នកជំនាញ Alexander HINTON (2-TCE-88) ជាពិសេស ទាក់ទិននឹងការអះអាងរបស់គាត់ដែលថា ការប្រើពាក្យ "យួន" គឺជាការញុះញង់ឲ្យមានអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិវៀតណាមក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ មេធាវីការពារក្តីបានលើកឡើងបន្ថែមថា សម្ភារៈនេះអាចជួយអង្គជំនុំជម្រះ ក្នុងការប្រៀបធៀបរវាងសុន្ទរកថារបស់សម្តេចព្រះបរមរតនកោដ្ឋ និង "សេចក្តីថ្លែងការណ៍របស់ ប.ក.ក" និង អាចត្រូវបានធ្វើឡើងចំពោះជំហរលើប្រទេសវៀតណាម និង ជនជាតិវៀតណាម ក៏ដូចជាការប្រើប្រាស់ពាក្យ "យួន"។ បន្ថែមពីលើនេះ *ក្នុងចំណោមមូលហេតុផ្សេងៗទៀត* សម្ភារៈទាំងនេះនឹងផ្តល់ដល់អង្គជំនុំជម្រះសាលាដំបូងនូវបរិបទប្រវត្តិសាស្ត្រ និង នយោបាយ ជុំវិញចេតនានៃការប្រើប្រាស់ពាក្យមួយចំនួនក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ឯកសារ E396 កថាខណ្ឌ ៦-៧, ១២-១៣, ១៧-១៨ ឯកសារ E396/3 កថាខណ្ឌ ១១)។ មេធាវីការពារក្តី ខៀវ សំផន គាំទ្រសំណើសុំនេះ ដោយយល់ស្របថា សម្ភារៈនេះអាចទទួលយកធ្វើជាភស្តុតាង និង ពាក់ព័ន្ធនឹងការវាយតម្លៃលើសក្ខីកម្មរបស់អ្នកជំនាញ HINTON (2-TCE-88) (ឯកសារ E396/1 កថាខណ្ឌ ៤)។

៣. ទោះបីជាសម្ភារៈនេះ អាចរកបានជាសាធារណៈមុនពេលចាប់ផ្តើមការជំនុំជម្រះក៏ដោយ ក៏មេធាវីការពារក្តី នួន ជា សន្និដ្ឋានថា សំណើសុំនេះត្រូវបានដាក់ទាន់ពេលវេលា ព្រោះវាត្រូវបានជំរុញដោយសក្ខីកម្មរបស់លោក HINTON (2-TCE-88) ទាក់ទិននឹងសុន្ទរកថារបស់សម្តេចព្រះបរមរតនកោដ្ឋ នៅឯក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ នាថ្ងៃទី ១១ ខែ មករា ឆ្នាំ ១៩៧៩ ("សុន្ទរកថានៅ ក.ស.អ.ស.ប") ដែលមេធាវីការពារក្តីមិនអាចប្រមើលមើលដឹងជាមុនបាន (ឯកសារ E396 កថាខណ្ឌ ១៩)។

៤. សហព្រះរាជអាជ្ញាលើកឡើងថា សម្ភារៈនេះមិនបានជួយក្នុងការវាយតម្លៃពីភាពអាចជឿជាក់

បានរបស់លោក HINTON (2-TCE-88) នោះឡើយ ហើយថា មតិយោបល់របស់សម្តេចព្រះបរមរតនកោដ្ឋ ពាក់ព័ន្ធនឹងចេតនារបស់វៀតណាមក្នុងការដាក់កម្ពុជាជាចំណុះប្រទេសវៀតណាមនៅក្រោយរបបកម្ពុជាប្រជាធិបតេយ្យ និង ការប្រើពាក្យ "យួន" របស់ព្រះអង្គមិនពាក់ព័ន្ធឡើយ ហេតុនេះ វាមិនមានតម្លៃជាភស្តុតាង ទាក់ទិននឹងការប្រព្រឹត្តិចំពោះជនជាតិវៀតណាមក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ និង ការចោទប្រកាន់ផ្សេងៗប្រឆាំងនឹងជនជាប់ចោទនោះទេ។ ត្រង់ចំណុចនេះ សហព្រះរាជអាជ្ញាកត់សម្គាល់ថា សម្ភារៈនេះទាក់ទិននឹងសេចក្តីថ្លែងការណ៍ និង មតិយោបល់ដែលសម្តេចព្រះបរមរតនកោដ្ឋ បានធ្វើនៅក្រោយរបបកម្ពុជាប្រជាធិបតេយ្យហើយវាមិនស្ថិតនៅក្នុងបរិបទនៃរបបនេះនោះឡើយ (ឯកសារ E396/2 កថាខណ្ឌ ២-៥)។

៥. ក្នុងការឆ្លើយតប មេធាវីការពារក្តី នួន ជា លើកឡើងបន្ថែមថា ដោយមិនគិតដល់ភាពពាក់ព័ន្ធរបស់សម្ភារៈទាំងនេះទៅនឹងភាពអាចជឿជាក់បានរបស់លោក HINTON (2-TCE-88) សម្ភារៈទាំងនេះអាចទទួលយកបាន ដោយសារវាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងសុន្ទរកថា នៅ ក.ស.អ.ស.ប ដែលមាននៅចំពោះមុខអង្គជំនុំជម្រះរួចហើយ និង មេធាវីការពារក្តីស្នើសុំឱ្យយកធ្វើជាភស្តុតាង (ឯកសារ E396/3 កថាខណ្ឌ ៥)។

៦. អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង នៅគ្រប់ដំណាក់កាលនៃនីតិវិធីទាំងអស់ អង្គជំនុំជម្រះអាចទទួលយកនូវភស្តុតាងទាំងឡាយណា ដែលអង្គជំនុំជម្រះយល់ឃើញថាមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត នៅពេលដែលភស្តុតាងនោះក៏បំពេញផងដែរនូវបទដ្ឋាន*ការបញ្ជាក់បឋម* នៃភាពពាក់ព័ន្ធ ភាពអាចជឿជាក់បាន និង យថាភាព ដែលតម្រូវដោយវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះនឹងសម្រេចលើសំណើសុំឱ្យទទួលយកភស្តុតាងថ្មី ស្របតាមលក្ខណៈវិនិច្ឆ័យដូចមានចែងនៅក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។ វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ក៏តម្រូវផងដែរថា ភាគីដែលស្នើសុំឱ្យទទួលយកភស្តុតាងថ្មីត្រូវបញ្ជាក់ពីមូលហេតុនៃការស្នើសុំនេះឱ្យបានច្បាស់លាស់។ ភាគីដែលស្នើសុំត្រូវធ្វើឱ្យអង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា ភស្តុតាងដែលខ្លួនបានស្នើសុំដាក់នោះ មិនអាចរកបាននៅមុនពេលចាប់ផ្តើមការជំនុំជម្រះ ឬ មិនអាចត្រូវបានរកឃើញ ទោះបីជាបានយកចិត្តទុកដាក់សមស្របហើយក៏ដោយ។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងករណីមួយចំនួន អង្គជំនុំជម្រះ

សាលាដំបូងបានទទួលយកភ័ស្តុតាងនានា ដែលពុំបានបំពេញទៅតាមលក្ខណៈវិនិច្ឆ័យនេះឡើយ រួមទាំងក្នុងករណីដែលភ័ស្តុតាងពាក់ព័ន្ធយ៉ាងជិតស្និទ្ធជាមួយនឹងសម្ភារៈដែលមានរួចហើយនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និង ក្នុងករណីដែលប្រយោជន៍នៃយុត្តិធម៌តម្រូវឱ្យមានការវាយតម្លៃប្រភពទាំងនេះរួមគ្នា និង ករណីដែលឯកសារដែលបានស្នើសុំនេះ គឺជាភ័ស្តុតាងដោះបន្ទុក ដែលតម្រូវឱ្យមានការវាយតម្លៃ ដើម្បីជៀសវាងកំហុសក្នុងការស្វែងរកយុត្តិធម៌ (ឯកសារ E276/2 កថាខណ្ឌ ២ យោងទៅឯកសារ E190 និង E172/24/5/1, ឯកសារ E260 កថាខណ្ឌ ៥)។

៧. អង្គជំនុំជម្រះសូមរម្លឹកដល់ភាគីនានាថា ភាគីគួរគោរពតាមការអនុវត្តដែលបានកំណត់នាពេលកន្លងមក ស្តីអំពីការដាក់ឯកសារដែលត្រូវប្រើប្រាស់នៅក្នុងពេលស្តាប់សក្ខីកម្មរបស់សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី ឬ អ្នកជំនាញណាម្នាក់ ដែលត្រូវដាក់យ៉ាងហោចណាស់ពីរសប្តាហ៍មុនពេលសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី ឬ អ្នកជំនាញនោះ មកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះ (ឯកសារ E337/3 កថាខណ្ឌ ៣)។ ក្នុងករណីនេះ មេធាវីការពារក្តី នួន ជា បានទទួលការជូនដំណឹងយូរហើយអំពីការបង្ហាញខ្លួនរបស់លោក HINTON (2-TCE-88) ទោះជាយ៉ាងណា មេធាវីការពារក្តី បានដាក់សំណើសុំរបស់ខ្លួន ក្រោយពេលអ្នកជំនាញរូបនេះបានផ្តល់សក្ខីកម្មរួចហើយ។ អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានជូនដំណឹងដល់ភាគីថា អង្គជំនុំជម្រះនឹងមិនទទួលយកសំណើសុំដែលដាក់មិនទាន់ពេលឡើយ ជាពិសេសចំពោះសំណើសុំឱ្យទទួលយកសម្ភារៈដែលអាចរកបានជាសាធារណៈជាយូរមកហើយនោះ (ឯកសារ E387/3 កថាខណ្ឌ ១៨)។

៨. អង្គជំនុំជម្រះកត់សម្គាល់ថា សម្ភារៈដែលភាគីស្នើសុំឱ្យទទួលយកជាភ័ស្តុតាងទាំងនេះ អាចរកបានមុនពេលចាប់ផ្តើមការជំនុំជម្រះក្នុងសំណុំរឿង ០០២ នៅខែ មិថុនា ឆ្នាំ ២០១១។ ហេតុនេះ សម្ភារៈនេះគួរតែត្រូវបានរកឃើញបានឆាប់ជាងនេះ ប្រសិនបើមានការខិតខំព្យាយាមបំពេញការងារនោះ។ ផ្ទុយទៅនឹងការសន្និដ្ឋានរបស់មេធាវីការពារក្តី នួន ជា ដែលថា សំណើសុំត្រូវបាន "ជំរុញដោយសក្ខីកម្មរបស់ HINTON (2-TCE-88) ទាក់ទិននឹងសុន្ទរកថារបស់សម្តេចព្រះបរមរតនកោដ្ឋ នៅ ក.ស.អ.ស.ប" អង្គជំនុំជម្រះកត់សម្គាល់ថា ភ័ស្តុតាងទាក់ទិននឹងទស្សនៈរបស់ HINTON (2-TCE-88) អំពីការយល់ឃើញចំពោះជនជាតិវៀត-

ណាម ដូចដែលនឹងពិភាក្សាខាងក្រោម គួររកបានតាំងពីពេលចាប់ផ្តើមកិច្ចដំណើរការជំនុំ-ជម្រះម្ល៉េះ។ ហេតុនេះ អង្គជំនុំជម្រះសន្និដ្ឋានថា សំណើនេះមិនត្រូវបានដាក់ទាន់ពេលវេលា។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះនឹងពិចារណាថា តើការទទួលយកសម្ភារៈនេះជាភ័ស្តុតាង គឺជាប្រយោជន៍នៃយុត្តិធម៌ដែរ ឬ យ៉ាងណា ។

៩. ផ្ទុយទៅនឹងសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តី នួន ជា អង្គជំនុំជម្រះសាលាដំបូងសន្និដ្ឋានថា វាមិនមែនជាប្រយោជន៍នៃយុត្តិធម៌ ក្នុងការទទួលយកសម្ភារៈទាំងនេះធ្វើជាភ័ស្តុតាង ដើម្បីធ្វើការប្រៀបធៀបរវាងសុន្ទរកថារបស់សម្តេចព្រះបរមរតនកោដ្ឋ និង "សេចក្តីថ្លែងរបស់ ប.ក.ក" ក្នុងគោលបំណងពិនិត្យមើលជំហររបស់ ប.ក.ក ចំពោះប្រទេសវៀតណាម និង ជនជាតិវៀតណាម ក៏ដូចជាការប្រើប្រាស់ពាក្យ "យួន" នោះឡើយ។ អង្គជំនុំជម្រះកត់សម្គាល់ថា មេធាវីការពារក្តី នួន ជា ទេ ដែលថា មានភាពស្រដៀងគ្នាបែបនេះ ចំណែកលោក HINTON (2-TCE-88) បានផ្តល់សក្ខីកម្មថា មិនគួរធ្វើការប្រៀបធៀប "សុន្ទរកថា" របស់សម្តេចព្រះបរមរតនកោដ្ឋ ជាមួយនឹងសេចក្តីថ្លែងរបស់ ប.ក.ក នោះទេ ដោយសារ "មានលក្ខណៈខុសគ្នាខ្លាំង" ទាំងខ្លឹមសារ ទាំងពេលវេលា និង កាលៈទេសៈ (ឯកសារ E1/403.1 ប្រតិចារឹកសវនាការ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៦ ទំព័រ ៣៣)។ អង្គជំនុំជម្រះសន្និដ្ឋានថា ការប្រៀបធៀបនេះ មិនមានសារៈប្រយោជន៍ និង ពាក់ព័ន្ធសោះឡើយ ដោយសារការថ្លែងការណ៍ទាំងនោះ ធ្វើឡើងនៅក្នុងពេលវេលា និង បរិបទប្រវត្តិសាស្ត្រខុសគ្នា។ ចុតហ្មាយ និង សុន្ទរកថានេះ ត្រូវបានសរសេរនៅក្រោយថ្ងៃទី ០៧ ខែ មករា ឆ្នាំ ១៩៧៩ ជាច្រើនខែ ឬ ជាច្រើនឆ្នាំ នៅក្នុងអំឡុងពេលដែលកងទ័ពវៀតណាមបោះទីតាំងជាអចិន្ត្រៃយ៍ជាច្រើនកន្លែងនៅលើទឹកដីកម្ពុជា។ ពាក់ព័ន្ធនឹងការប្រើប្រាស់ពាក្យ "យួន" សម្ភារៈទាំងនេះបានបង្ហាញថា សម្តេចព្រះបរមរតនកោដ្ឋ មិនបានប្រើប្រាស់ពាក្យនេះនៅក្នុងចុតហ្មាយផ្លូវការឡើយ។ បន្ថែមពីលើនេះ បរិបទនៃការប្រើប្រាស់ពាក្យ "យួន" នៅក្នុងសុន្ទរកថានៅក្នុងខ្សែវីដេអូ និង ខ្សែអាត់សម្លេង មិនមានភាពច្បាស់លាស់នោះឡើយ ប៉ុន្តែ ការប្រើប្រាស់ពាក្យនេះពាក់ព័ន្ធទៅនឹងអំឡុងពេលមួយស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង ០០២/០២ និង មានភាពខុសគ្នាពីការប្រើពាក្យនេះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

១០. ហេតុនេះ អង្គជំនុំជម្រះសាលាដំបូងសន្និដ្ឋានថា សម្ភារៈដែលបានស្នើសុំនេះ មានភាពពាក់ព័ន្ធ

តិចតួចទៅនឹងការជំនុំជម្រះនាពេលនេះ ហើយអង្គជំនុំជម្រះកត់សម្គាល់បន្ថែមទៀតថាសំណុំរឿងបច្ចុប្បន្ន មានភស្តុតាងច្រើនរួចហើយ ដែលមានរួមទាំងភស្តុតាងពាក់ព័ន្ធនឹងទស្សនៈរបស់ HINTON (2-TCE-88) ចំពោះការយល់ឃើញទូទៅចំពោះជនជាតិវៀតណាម នៅមុន ក្នុងអំឡុងពេល និង ក្រោយរបបកម្ពុជាប្រជាធិបតេយ្យ ជាពិសេសទាក់ទិននឹងការប្រើប្រាស់ និង អត្ថន័យនៃពាក្យ "យួន" (*សូមមើល* ឧទាហរណ៍ ឯកសារ E3/3346, E3/2119, E3/2376, E3/7478)។ មេធាវីការពារក្តី នួន ជា គួរអាចរកភស្តុតាងនេះបាន នៅពេលសាកសួរលោក HINTON (2-TCE-88)។ ជាពិសេស អង្គជំនុំជម្រះកត់សម្គាល់បន្ថែមទៀតថា ភាគីបានស្តាប់ភស្តុតាងស្តីពីអត្ថន័យ និង ការប្រើប្រាស់ពាក្យ "យួន" នៅក្នុងសវនាការជាច្រើនដងរួចហើយ ជាពិសេសនៅក្នុងបរិបទនៃរបបកម្ពុជាប្រជាធិបតេយ្យ (*សូមមើល ឧទាហរណ៍* ប្រតិចារឹកសវនាការ ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៦ ទំព័រ ៤-៥, ២៣-២៤; ប្រតិចារឹកសវនាការ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១៦ ទំព័រ ៥១-៥៤; ប្រតិចារឹកសវនាការ ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៦ ទំព័រ ៩៣-៩៧)។ លោក HINTON (2-TCE-88) ក៏បានផ្តល់ភស្តុតាងលើបញ្ហានេះផងដែរ នៅពេលដែលគាត់បានមកផ្តល់សក្ខីកម្ម ហើយមេធាវីការពារក្តីបានសួរដេញដោលលើបញ្ហានេះរួចមកហើយ។ ហេតុនេះ អង្គជំនុំជម្រះសន្និដ្ឋានថា សម្ភារៈនេះ មិនជួយអង្គជំនុំជម្រះក្នុងការវាយតម្លៃពីភាពអាចជឿជាក់បានរបស់ HINTON (2-TCE-88) នោះឡើយ បន្ថែមលើនេះ វាមិនផ្តល់នូវភស្តុតាងបន្ថែមដែលពាក់ព័ន្ធទៅនឹងភស្តុតាងដែលត្រូវបានទទួលយករួចហើយទាក់ទិននឹងបញ្ហាទាំងនេះនោះឡើយ។ អង្គជំនុំជម្រះសន្និដ្ឋានថា មិនមានកាលៈទេសៈពិសេស ដូចមានលើកឡើងនៅក្នុងកថាខណ្ឌ ៦ ខាងលើ ដែលតម្រូវឲ្យទទួលយកសម្ភារៈនេះដើម្បីជាប្រយោជន៍នៃយុត្តិធម៌នោះឡើយ។

១១. អនុស្សរណៈនេះ ជាការឆ្លើយតបផ្លូវការទៅនឹងឯកសារ E396។